# ចាក់ថ្នាំវ៉ាក់សុីនបង្ការរោគរលាកថ្លើម A

## អ្វីដែលលោកអ្នកត្រូវដឹង

## 1 អ្វីដែលជារោគរលាកថ្លើម A នោះ ?

រោគរលាកថ្លើម A គឺជារោគថ្លើមធ្ងន់ធ្ងរមួយ ដែលកើតឡើងដោយមេរោគរលាកថ្លើម A (Hepatitis A Virus, HAV), មេរោគរលាកថ្លើម A (HAV) គឺមាននៅក្នុងលាមកមនុស្ស ដែលមានរោគរលាក ថ្លើម A នេះ។ ជាធម្មតារោគនេះអាចឆ្លងដោយសារការទាក់ទងជិតស្និតនឹងគ្នា ហើយជួនកាលដោយសារការបរិភោគម្ហូបអាហារ ឬផឹកទឹកដែលមានមេ រោគរលាកថ្លើមនេះតែម្តង។



រោគរលាកថ្លើម A អាចធ្វើអោយ :

- កើតជម្ងឺ "ដូច-គ្រុនផ្តាសាយ" មធ្យម
- កើតជម្ងឺខាន់លឿង (ស្បែក នឹងភ្នែកឡើងពណ៌លឿង)
- ឈឺពោះខ្លាំង ឬចុះរាគខ្លាំង

មនុស្សដែលកើតរោគរលាកថ្លើម A ភាគច្រើនបណ្តាលឲ្យដេកពេទ្យ (មានដល់មនុស្ស 1 នាក់ក្នុង ចំនួនមនុស្ស 5 នាក់)។

ជួនកាលមានមនុស្សស្លាប់ដោយសាររោគរលាកថ្លើម A នេះ (មានប្រមាណ 3-5 ករណីស្លាប់ ក្នុងចំណោមករណី 1,000)។

មនុស្សដែលមានរោគរលាកថ្លើម A អាចងាយចម្លងរោគនេះទៅមនុស្សដទៃទៀត នៅក្នុងផ្ទះរស់នៅ ជាមួយគ្នា។

**ការចាក់ថ្នាំវ៉ាក់សុីនបង្ការរោគរលាកថ្លើម A អាចការពាររោគនេះបាន។**

## 2 តើអ្នកណាត្រូវចាក់ថ្នាំវ៉ាក់សុីនបង្ការរោគរលាកថ្លើម A ហើយនៅពេលណា ?

**អ្នកណា ?**

មានមនុស្សខ្លះត្រូវចាក់ថ្នាំវ៉ាក់សុីនជាប្រចាំបង្ការរោគរលាកថ្លើម A :

- ក្មេងមានអាយុពី 1 ឆ្នាំ (12 ខែដល់ 23 ខែ)។
- មនុស្សមានអាយុពី 1 ឆ្នាំ និងមានអាយុច្រើនជាងនេះដែលធ្វើដំណើរ ឬប្រកបការងារនៅ ប្រទេសណាដែលមានអត្រារោគរលាកថ្លើម A ខ្ពស់ និងមធ្យមជាទូទៅ, ដូចជាប្រទេសស្ថិតនៅភូមិ ភាគអាមេរិកកណ្តាល ឬអាមេរិកខាងត្បូង, ប្រទេសម៉ិកស៊ិកូ, ទ្វីបអាស៊ី (លើកលែងតែប្រទេស ជប៉ុន), ទ្វីបអាហ្វ្រិក ហើយនិងខាងកើតនៃទ្វីបអឺរ៉ុប។ សំរាប់ពត៌មានបន្ថែម សូមទស្សនាគេហ ទំព័រកុំព្យូទ័រ **www.cdc.gov/travel** ។
- កូនក្មេងនិងមនុស្សពេញវ័យដល់អាយុ 18 ឆ្នាំដែលរស់នៅក្នុងរដ្ឋទាំងឡាយណា ឬសហគមន៍ ទាំងឡាយណាដែលតម្រូវឲ្យមានការចាក់ថ្នាំវ៉ាក់សុីនបង្ការរោគ ពីព្រោះមានគ្រោះថ្នាក់នៃរោគនេះ ខ្ពស់។
- បុរសដែលសេពកាមជាមួយនឹងបុរស។
- មនុស្សដែលប្រើប្រាស់គ្រឿងញៀនតាមផ្លូវ។
- មនុស្សដែលមានជម្ងឺថ្លើមរ៉ាំរ៉ៃ។
- មនុស្សដែលបានទទួលការព្យាបាលដោយសេការជាតិធ្វើឲ្យឈាមកក។
- មនុស្សដែលធ្វើការងារជាមួយវានរជាតិដែលមានមេរោគថ្លើម HAV ឬមនុស្សធ្វើការងារនៅមន្ទីរ ស្រាវជ្រាវមេរោគ HAV ។

មនុស្សផ្សេងទៀត ដែលទទួលចាក់ថ្នាំវ៉ាក់សុីនបង្ការរោគរលាកថ្លើម A នៅក្នុងកាលៈទេសៈពិសេស ណាមួយ :

- ថ្នាំវ៉ាក់សុីនចាក់បង្ការរោគរលាកថ្លើម A ប្រហែលជាតម្រូវឲ្យចាក់ឲ្យកូនក្មេង ឬមនុស្សពេញវ័យ ដែលរស់នៅក្នុងសហគមន៍ដែលមាន កើតរោគរលាកថ្លើម A រាលដាល។

*ការចាក់ថ្នាំវ៉ាក់សុីនបង្ការរោគរលាកថ្លើម A គឺមិនមានការចេញច្បាប់អនុញ្ញាតឲ្យចាក់សំរាប់ក្មេង មានអាយុក្រោម 1 ឆ្នាំឡើយ។*

**នៅពេលណា ?**

ចំពោះកូនក្មេង, ការចាក់ថ្នាំបង្ការដំបូងត្រូវផ្តល់ឲ្យនៅពេលក្មេងមានអាយុពី 12-23 ខែ។ ចំណែក កូនក្មេងដែលមិនបានចាក់ថ្នាំបង្ការរោគរហូតដល់មានអាយុ 2 ឆ្នាំ អាចចាក់ថ្នាំវ៉ាក់សុីនបង្ការរោគនេះ បាននៅពេលមកជួបពេទ្យលើកក្រោយ។

ចំពោះអ្នកធ្វើដំណើរ, ការចាក់ថ្នាំវ៉ាក់សុីនជាបន្តបន្ទាប់គួរតែចាប់ផ្តើមចាក់ឲ្យបានមួយខែ មុនពេល ធ្វើដំណើរដើម្បីឲ្យមានសុវត្ថិភាពការពារបានល្អបំផុត។

> ចំពោះមនុស្សណាដែលចាក់ថ្នាំវ៉ាក់សុីនបង្ការរោគមិនទាន់បានមួយខែមុនពេលធ្វើដំណើរ ក៏អាចចាក់ ថ្នាំមួយទៀតហៅថា immune globulin (IG) បានដែរ។ ថ្នាំ IG ផ្តល់នូវសុវត្ថិភាពការពារបណ្តោះ អាសន្នបានភ្លាមៗ។

ចំពោះមនុស្សផ្សេងៗទៀត, ការចាក់ថ្នាំវ៉ាក់សុីនបង្ការរោគរលាកថ្លើម A ជាបន្តបន្ទាប់អាចចាប់ផ្តើម ចាក់នៅពេលមនុស្សនោះទំនងមានមេរោគនេះ។

**ត្រូវចាក់ពីរលើក**នៃថ្នាំវ៉ាក់សុីនសំរាប់ការពារមេរោគនេះរហូត។ ការចាក់ថ្នាំនេះត្រូវប្រព្រឹត្តធ្វើឡើង 6 ខែម្តង។

ថ្នាំវ៉ាក់សុីនចាក់បង្ការរោគរលាកថ្លើម A អាចចាក់ឲ្យនៅពេលចាក់ថ្នាំវ៉ាក់សុីនដទៃទៀតបាន។

## 3 មានមនុស្សខ្លះ មិនគួរចាក់ថ្នាំវ៉ាក់សុីនបង្ការរោគរលាកថ្លើម A ឬ គួររង់ចាំ

- មនុស្សដែលធ្លាប់មាន (ភាពគ្រោះថ្នាក់ដល់អាយុជីវិត) **ប្រតិកម្មទាស់ធ្ងន់ធ្ងរចំពោះថ្នាំបង្ការរោគ រលាកថ្លើម A ពីមុនមក** មិនគួរចាក់ថ្នាំវ៉ាក់សុីនទៀតទេ។

- ចំពោះមនុស្សដែលមាន (ភាពគ្រោះថ្នាក់ដល់អាយុជីវិត) **ប្រតិកម្មធ្ងន់ធ្ងរប្រឆាំងនិងប្រភេទថ្នាំវ៉ាក់សាំងណា**មួយ មិនគួរចាក់ថ្នាំវ៉ាក់សាំងនេះទេ។ ចូរប្រាប់វេជ្ជបណ្ឌិតរបស់លោកអ្នក បើសិនជាលោកអ្នកមានប្រតិកម្មថ្នាំធ្ងន់ធ្ងរនោះ។ ថ្នាំវ៉ាក់សាំងចាក់បង្ការរោគរលាកថ្លើម A ទាំងអស់មានជាតិសាច់ជូរ ហើយនិងថ្នាំវ៉ាក់សាំងបង្ការ រោគរលាកថ្លើម A ខ្លះទៀតមានជាតិ 2-ហ្វីណូស៊ីយ៉េតថាណុល (2-phenoxyethanol)។
- ចំពោះមនុស្សដែល**ឈឺល្មម ឬធ្ងន់ធ្ងរ** នៅពេលដែលត្រូវចាក់ថ្នាំ គួរតែរង់ចាំរហូតដល់ជម្ងឺនោះជា សះស្បើយសិន មុននឹងចាក់ថ្នាំនេះ។ ចូរសាកសួរវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាករបស់លោកអ្នក។ មនុស្សដែល**ជម្ងឺឈឺមធ្យម** ជាទូទៅអាចចាក់ថ្នាំវ៉ាក់សាំងបាន។
- ចូរប្រាប់វេជ្ជបណ្ឌិតលោកអ្នក បើសិនជាលោកអ្នកមាន**ផ្ទៃពោះ**។ សុវត្ថិភាពនៃការចាក់ថ្នាំវ៉ាក់សាំង បង្ការរោគរលាកថ្លើម A សំរាប់ស្ត្រីមានផ្ទៃពោះ គឺមិនទាន់រកឃើញនៅឡើយទេ។ ក៏ប៉ុន្តែ គ្មាន ភស្តុតាងណាមួយបង្ហាញឲ្យឃើញថា ភាពមានសេចក្តីអន្តរាយដល់ស្ត្រីមានផ្ទៃពោះ ឬទារកនៅ ក្នុងផ្ទៃនោះឡើយ។ ភាពអន្តរាយ បើសិនជាមាន គឺមានតិចតួចណាស់។

## 4 តើភាពអន្តរាយពីការចាក់ថ្នាំវ៉ាក់សាំងបង្ការរោគរលាកថ្លើម A ជាអ្វីដែរ ?

ថ្នាំចាក់វ៉ាក់សាំង ដូចថ្នាំដទៃៗទៀតអញ្ចឹង ថ្នាំនេះប្រហែលជាអាចធ្វើឲ្យមានបញ្ហាធ្ងន់ធ្ងរ ដូចជាមាន ប្រតិកម្មទាស់ថ្នាំធ្ងន់ធ្ងរ។ ភាពអន្តរាយនៃការចាក់ថ្នាំវ៉ាក់សាំងបង្ការរោគរលាកថ្លើម A ដែលអាចធ្វើឲ្យ មានគ្រោះថ្នាក់ធ្ងន់ធ្ងរ ឬអាចស្លាប់នោះ គឺមានតិចតួចណាស់។

ការចាក់ថ្នាំវ៉ាក់សាំងបង្ការរោគរលាកថ្លើម A គឺមានសុវត្ថិភាពល្អ ជាជាងការកើតមានមេរោគនេះ។

**បញ្ហាល្មម**

- ឈឺត្រង់កន្លែងចាក់ថ្នាំ *(មានមនុស្សចាស់ 1 នាក់ ក្នុងចំណោមមនុស្សចាស់ 2 ពីរនាក់, ហើយមានក្មេង 1 នាក់ ក្នុងចំណោមក្មេង 6 នាក់)*
- ឈឺក្បាល *(មានមនុស្សចាស់ 1 នាក់ ក្នុងចំណោមមនុស្សចាស់ 6 នាក់, និងមានក្មេង 1 នាក់ ក្នុង ចំណោមក្មេង 25 នាក់)*
- បរិភោគម្ហូបអាហារមិនបាន *(មានក្មេង 1 នាក់ក្នុងចំណោមក្មេង 12 នាក់)*
- អស់កម្លាំង *(មានមនុស្សចាស់ 1 នាក់ក្នុងចំណោមមនុស្សចាស់ 14 នាក់)*

បើសិនជាលោកអ្នកមានបញ្ហាទាំងនេះកើតឡើង ជាទូទៅច្រើនឈឺពី 1-2 ថ្ងៃ។

**បញ្ហាធ្ងន់ធ្ងរ**

- មានប្រតិកម្មទាស់ធ្ងន់ធ្ងរ ពីរបីនាទីទៅពីរបីម៉ោង ក្រោយពីបានចាក់ថ្នាំនេះហើយ *(កម្រមានណាស់)*

## 5 ចុះបើសិនជាមានប្រតិកម្មទាស់មធ្យម ឬធ្ងន់ធ្ងរនោះ ?

**តើឲ្យខ្ញុំសំគាល់មើលអ្វី ?**

- បើមានបុព្វហេតុមិនធម្មតា ដូចជាគ្រុនក្តៅខ្លាំង ឬផ្លាស់ប្តូរអាកប្បកិរិយា។ សញ្ញាសំគាល់ប្រតិកម្ម ទាស់ធ្ងន់ធ្ងរ អាចរួមចូលការពិបាកដកដង្ហើម, ស្អកសម្លេង ឬដង្ហើមតឹងៗ, កន្ទួលរមាស់, ស្លេក ស្លាំង, ខ្សោយ, បេះដូងដើរញាប់ ឬវិលមុខ។

**តើគួរឲ្យខ្ញុំធ្វើយ៉ាងណា ?**

- **ទូរស័ព្ទ**ទៅវេជ្ជបណ្ឌិត ឬយកមនុស្សនោះទៅជួបវេជ្ជបណ្ឌិតពិនិត្យមើលភ្លាម។
- **ប្រាប់**វេជ្ជបណ្ឌិតនូវអ្វីដែលបានកើតឡើង ខែថ្ងៃឆ្នាំ ហើយនិងម៉ោងបុព្វហេតុកើតឡើង ហើយ ពេលបានចាក់ថ្នាំវ៉ាក់សាំងនៅពេលណា។
- **សាកសួរ**វេជ្ជបណ្ឌិត, គិលានុបដ្ឋាក ឬមន្ទីរសុខាភិបាល ដើម្បីឲ្យគេបំពេញក្រដាសរាយព្រឹត្តិ ការណ៍ប្រព័ន្ធថ្នាំវ៉ាក់សាំង (Vaccine Adverse Event Reporting System (VAERS)) ។

ឬលោកអ្នកអាចបំពេញក្រដាសរាយព្រឹត្តិការណ៍តាមគេហទំព័រ VAERS នៅ www.vaers.hhs.gov, ឬ ទូរស័ព្ទមកលេខ 1-800-822-7967 ក៏បាន។

*ភ្នាក់ងារ VAERS មិនមានផ្តល់ឱវាទពីការព្យាបាលសុខភាពទេ។*

## 6 កម្មវិធីជាតិចេញថ្លៃព្យាបាលជម្ងឺដោយគ្រោះថ្នាក់ពីថ្នាំវ៉ាក់សាំង

នៅក្នុងព្រឹត្តិការណ៍ដែលលោកអ្នក ឬកូនរបស់លោកអ្នកមានប្រតិកម្មទាស់ទៅនិងថ្នាំវ៉ាក់សាំងធ្ងន់ធ្ងរ, កម្មវិធីរដ្ឋាភិបាលបានបង្កើតឡើងដើម្បីជួយបង់ថ្លៃព្យាបាលដល់មនុស្សណាដែលបានទទួលការ គ្រោះថ្នាក់នេះ។

ដើម្បីទទួលពត៌មានល្អិតល្អន់អំពីកម្មវិធីជាតិសងជម្ងឺនៃការគ្រោះថ្នាក់ពីថ្នាំវ៉ាក់សាំង (National Vaccine Injury Compensation Program), សូមទូរស័ព្ទមកលេខ 1-800-338-2382 ឬទស្សនាគេហទំព័រកុំព្យូទ័រ www.hrsa.gov/vaccinecompensation ។

## 7 តើអោយខ្ញុំសិក្សាបន្ថែមអំពីបញ្ហានេះដោយរបៀបណា ?

- សួរវេជ្ជបណ្ឌិត ឬគិលានុបដ្ឋាក។ គេអាចផ្តល់ឲ្យលោកអ្នកនូវក្រដាសពត៌មានក្នុងកញ្ចប់ថ្នាំវ៉ាក់សាំង ឬឲ្យយោបល់អំពីប្រភពពត៌មានផ្សេងៗទៀត។
- ទូរស័ព្ទមកក្រសួងសុខាភិបាលតំបន់ ឬរដ្ឋ។
- ចូរទាក់ទងមកក្រសួងត្រួតពិនិត្យ និងការពាររោគ (CDC) :
  - ទូរស័ព្ទលេខ **1-800-232-4636 (1-800-CDC-INFO)**
  - បើកមើលគេហទំព័រកុំព្យូទ័រ CDC នៅ **www.cdc.gov/hepatitis** ឬគេហទំព័រ **www.cdc.gov/nip**

Vaccine Information Statement
Hepatitis A IMM-502 - Cambodian (3/21/06) 42 U.S.C. § 300aa-26
Translated by Transcend, Davis, CA www.transcend.net

CDC

DEPARTMENT OF HEALTH AND HUMAN SERVICES
CENTERS FOR DISEASE CONTROL AND PREVENTION
NATIONAL IMMUNIZATION PROGRAM